# ក្រុមអ្នកតស៊ូមតិកម្ពុជា
# CAMBODIAN ADVOCACY TEAM (CAT)

ទីក្រុងម៉ែលប៊ិន ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤

## សេចក្តីវិភាគផ្លូវច្បាប់
## អំពី ការចាប់ខ្លួនលោក ម៉ិច ដារ៉ា អ្នកសារព័ត៌មានឯករាជ្យ

អ្នកសារព័ត៌មានឯករាជ្យ លោក **ម៉ិច ដារ៉ា** ត្រូវបានកងកម្លាំងសមត្ថកិច្ចរបស់ប្រទេសកម្ពុជាចាប់ខ្លួននៅពេលលោក និងក្រុមគ្រួសារកំពុងបង់ប្រាក់នៅតាមផ្លូវធ្វើដំណើរដោយរថយន្តនៅខេត្តកោះកុង ហើយសមត្ថកិច្ចបញ្ជូនលោកទៅសាលាដំបូង រាជធានីភ្នំពេញដាក់ចូលក្នុងទម្រង់នីតិវិធីសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយមិនទាន់មានការសម្រេចរបស់តុលាការតាមរយៈសាលក្រមនៅឡើយ ។

តាមសេចក្តីប្រកាសព័ត៌មានរបស់សាលាដំបូងរាជធានីភ្នំពេញចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៤ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញសម្រេចចោទប្រកាន់លោក ម៉ិច ដារ៉ា ពីបទ ញុះញង់បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ប្រព្រឹត្តនៅរាជធានីភ្នំពេញ និងបណ្តាញសង្គម កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២៤ និងពេលបន្តបន្ទាប់ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤៩៤ និង មាត្រា ៤៩៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

តាមអង្គហេតុ និង បទបញ្ញត្តិចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៦៤៣៨ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ តាមមាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបអង្កេតមានតួនាទីស៊ើបសួររកភាពច្បាស់លាស់ នៃអង្គហេតុ និង នីតិវិធីចាប់ខ្លួននៅខេត្តកោះកុង ការបញ្ជូនខ្លួនមករាជធានីភ្នំពេញ ភស្តុតាងដាក់បន្ទុក ភស្តុតាងដោះបន្ទុក និង ការសម្រេចឃុំខ្លួនដកហូតសេរីភាព ។

តាមរដ្ឋធម្មនុញ្ញ និង នីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា លោក ម៉ិច ដារ៉ា នៅតែជាជនឥតទោសលុះត្រាតែមានសាលក្រមស្ថាពរ ក៏ប៉ុន្តែជាក់ស្តែង លោក ម៉ិច ដារ៉ា ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នមុនសវនាការតាមការស្នើសុំរបស់តំណាងអយ្យការ ។

តាមព័ត៌មាន រហូតដល់ពេលនេះ លោក មុិច ដារ៉ា មិនដែលបានទទួលឬបដិសេធមិនទទួលម្តងណាឡើយនូវដីកាតុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៦៤៣៨ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ចសម្រេចចាប់និងនាំខ្លួន លោក មុិច ដារ៉ា គឺលុះត្រាតែជាបទល្មើសជាក់ស្តែង ។ ក៏ប៉ុន្តែជាអង្គហេតុជាក់ស្តែង លោក មុិច ដារ៉ា និង ក្រុមគ្រួសារ កំពុងធ្វើដំណើរតាមរថយន្តនិងបង់ប្រាក់នៅបញ្ជរបង់ប្រាក់ផ្លូវជាតិនៅខេត្តកោះកុង ដែលមិនមានអង្គហេតុណាមួយកំពុងប្រព្រឹត្តបទល្មើសជាក់ស្តែងទេ ។

កំណត់ហេតុចាប់ខ្លួនលោក មុិច ដារ៉ា អាចបញ្ជាក់ពីអង្គហេតុកើតឡើង រួមទាំងទីកន្លែងចាប់ខ្លួន នៅខេត្តកោះកុង ហេតុការចាប់ខ្លួនផង ។ តាមបទចោទពីបទញុះញង់បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គមប្រព្រឹត្តនៅរាជធានីភ្នំពេញ និង បណ្តាញសង្គម កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២៤ និង ពេលបន្តបន្ទាប់ គឺបញ្ជាក់ថាអំពើរបស់លោក មុិច ដារ៉ា ដែលរងការចោទប្រកាន់ បានកើតឡើងនៅរាជធានីភ្នំពេញ និង ក្នុងបណ្តាញសង្គម ។

អំពីទីកន្លែង និងពេលវេលាកើតហេតុ ក្នុងបទចោទក្នុងសំណុំរឿងនេះ មិនមានភាពច្បាស់លាស់ដែលសាធារណជនអាចយល់ថា អង្គហេតុញុះញង់ប្រព្រឹត្តតាមបទចោទនោះ កើតនៅទីកន្លែងណាក្នុងរាជធានីភ្នំពេញ មានដូចជាទីតាំងកើតហេតុ ផ្ទះលេខ សង្កាត់ ខណ្ឌ នៃរាជធានីភ្នំពេញ និងប្រព្រឹត្តនៅពេលណាច្បាស់លាស់។ ពេលវេលាកើតហេតុ គឺត្រូវតែច្បាស់លាស់ជានិច្ច ដែលមិនអាចធ្វើការចោទប្រកាន់ប្រហាក់ប្រហែល ឬ ចោទប្រកាន់សរុបពេលវេលាដោយគ្មានបញ្ជាក់ពេលវេលាកើតហេតុច្បាស់លាស់បានឡើយ ។

ក្នុងន័យនេះ ពេលវេលាកើតហេតុដែលចោទប្រកាន់ថា លោក មុិច ដារ៉ា បានប្រព្រឹត្តអំពើញុះញង់ឲ្យមានភាពវឹកវរដល់សន្តិសុខសង្គម កើតនៅម៉ោងប៉ុន្មាន ថ្ងៃណា ខែណា ឆ្នាំណាឲ្យជាក់លាក់ ។ នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់សាលាដំបូងរាជធានីភ្នំពេញ ប្រកាសថា កើតឡើងអំឡុងខែកញ្ញា និង បន្តបន្ទាប់ ។ តាមព័ត៌មាននេះ ការចោទប្រកាន់មិនមានបញ្ជាក់ពេលវេលាច្បាស់លាស់ទេ ហេតុនេះ លោកមុិច ដារ៉ា មានសិទ្ធិដឹងពីពេលវេលាចោទប្រកាន់ច្បាស់លាស់ ទាំងម៉ោង ថ្ងៃ ខែ និង ឆ្នាំ ដើម្បីធ្វើការតទល់ស្វែងរកការពិតតាមនីតិវិធីព្រហ្មទណ្ឌ ។

បទចោទដែលត្រូវបានប្ដឹងដោយតំណាងអយ្យការដែលជាម្ចាស់បណ្ដឹងអាជ្ញា គឺ មាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។ ទាំងក្រសួងព័ត៌មាន ទាំងអាជ្ញាធរ ទាំងអ្នកនាំពាក្យរាជរដ្ឋាភិបាល បានអះអាងថា ការចាប់ខ្លួនលោក ម៉ិច ដារ៉ា មិនពាក់ព័ន្ធនឹងវិជ្ជាជីវៈសារព័ត៌មានទេ តែជាការអនុវត្តច្បាប់ព្រហ្មទណ្ឌ ។

**ក្រុមអ្នកតស៊ូមតិកម្ពុជា** (CAT) សូមវិភាគឈរលើមូលដ្ឋានមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ដែលតំណាងអយ្យការបានសម្រេចចោទប្រកាន់ប្ដឹងនិងស្ថិតក្នុងដៃចៅក្រមស៊ើបសួរ ។

១- តើតំណាងអយ្យការមានភស្ដុតាងមកបញ្ជាក់ថា អំពើញុះញង់ដែលលោក ម៉ិច ដារ៉ា បានប្រព្រឹត្តកើតនៅទីកន្លែងណា និង ពេលណាជាក់លាក់ដែលច្បាប់ថា ជាអង្គហេតុ? តំណាងអយ្យការត្រូវមានភស្ដុតាងមកបញ្ជាក់យ៉ាងតិចចំនួន ៣ ៖

ទី១ គឺទីកន្លែងនិងពេលវេលាជាក់លាក់ដែលលោក ម៉ិច ដារ៉ា បានប្រព្រឹត្តអំពើញុះញង់ ។

ទី២ គឺអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្ដិសុខសង្គម ។ តើអំពើអ្វីខ្លះដែលតំណាងអយ្យការមានក្នុងសំណុំរឿងនិងមានភស្ដុតាងបញ្ជាក់ថា មានអំពើត្រូវបានប្រព្រឹត្ត ។ តើអំពើនោះបានបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្ដិសុខសង្គម នៅទីណា មានផលវិបាកអ្វីខ្លះដែលត្រូវបានជាប់ពាក់ព័ន្ធនឹងអំពើរបស់ លោក ម៉ិច ដារ៉ា ។ ចៅក្រមស៊ើបសួរមានតួនាទីស្វែងរកភស្ដុតាងឲ្យផុតការសង្ស័យថា ភាពវឹកវរធ្ងន់ធ្ងរដល់សន្ដិសុខសង្គម នោះមានអត្ថិភាពឬនៅ ឬគ្រាន់តែជាការសន្និដ្ឋានរបស់តំណាងអយ្យការ និង ការសម្រេចរបស់ចៅក្រមស៊ើបសួរ? ចៅក្រមស៊ើបសួរក៏មានតួនាទីរកភស្ដុតាងដោះបន្ទុកដែរថា ការចោទប្រកាន់ឬបណ្ដឹងរបស់តំណាងអយ្យការមិនត្រឹមត្រូវ ។ ប្រសិនបើមិនមានភស្ដុតាងមកបញ្ជាក់ក្នុងសំណុំរឿងអំពី ភាពវឹកវរធ្ងន់ធ្ងរដល់សន្ដិសុខសង្គម នោះ តំណាងអយ្យការដែលបានសម្រេចធ្វើការចោទប្រកាន់ គឺគ្មានភស្ដុតាង គ្មានអង្គហេតុ តែផ្អែកលើការសន្និដ្ឋានរបស់ខ្លួនទាំងស្រុង ។ ក្នុងករណីនេះ ការចាប់ខ្លួនលោក ម៉ិច ដារ៉ា ក្លាយទៅជាការចាប់ខ្លួនខុសច្បាប់ និង ជាការឃុំខ្លួនខុសច្បាប់ទាំងស្រុង ។

ទី៣ ការចោទប្រកាន់របស់តំណាងអយ្យការ ថា លោក ដារ៉ា បានប្រព្រឹត្ត "កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២៤ និង ពេលបន្តបន្ទាប់ "។ នៅក្នុងរឿងព្រហ្មទណ្ឌ តំណាងអយ្យការ មិនអាចសំអាងឬសន្និដ្ឋានទូទៅដោយគ្មាន

កាលបរិច្ឆេទនៃអង្គហេតុយ៉ាងនេះបានឡើយ ។ តំណាងអយ្យការមានតួនាទីថ្លឹងថ្លែងថា តើមានអំពើល្មើស មែនឬអត់ កើតនៅកន្លែងណា នៅពេលណានៃសប្តាហ៍ ម៉ោង ឬ អាចដល់នាទី ទៀតផង ។ ប្រសិនសេចក្តីសំអាងដោយគ្មានភាពច្បាស់លាស់ដូចមានក្នុងសេចក្តីប្រកាសព័ត៌មានរបស់សាលាដំបូងរាជធានីភ្នំពេញ នោះគឺនៅជាការសង្ស័យនៅឡើយ ដែលតាមច្បាប់របស់កម្ពុជា គឺត្រូវបានជាប្រយោជន៍ដល់លោក ម៉ិច ដារ៉ា ដែលអាចនិយាយបានថា ចៅក្រមស៊ើបសួរ មិនមានសិទ្ធិសម្រេចឃុំខ្លួន លោក ម៉ិច ដារ៉ា ជាបណ្តោះអាសន្ន មុនសវនាការបានទេ ។

យើងសូមពន្យល់បន្ថែមដូចខាងក្រោម ៖

លោក ម៉ិច ដារ៉ា ត្រូវបានចោទប្រកាន់ក្រោមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌពីបទល្មើសញុះញង់ឲ្យប្រព្រឹត្តបទល្មើស យើងត្រូវមើលធាតុផ្សំនៃបទល្មើសនេះ ដើម្បីកំណត់ថាលោក ម៉ិច ដារ៉ា ពិតជាបានប្រព្រឹត្តបទល្មើសនេះដែរឬទេ។ មាត្រា ៤៩៤ និង ៤៩៥ ចែងថា៖

មាត្រា ៤៩៤៖
ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្តន្ទាទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្ត៖
១. ដោយសំដីតាមប្រភេទណាក៏ដោយដែលប្រកាសនៅទីកន្លែងសាធារណៈឬនៅក្នុងពេលប្រជុំជាសាធារណៈ។
២. ដោយសំណេរឬគំនូរ តាមប្រភេទណាក៏ដោយដែលត្រូវផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬ តាំងឲ្យសាធារណជនមើល។
៣.ដោយគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់សាធារណជន។

មាត្រា ៤៩៥៖
អំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយដែលមានចែងក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ។

ធាតុផ្សំនៃបទញុះញង់ដោយផ្ទាល់គឺ៖

១. ការបន្លឺពាក្យសំដី, សំណេរ, ឬ គំនូរ ជាសាធារណៈ ឬ មធ្យោបាយផ្សាយជាសាធារណៈ

២. ពាក្យសំដី, សំណេ, ឬ គំនូររនោះ៖

    ២.១ អំពាវនាវឲ្យប្រព្រឹត្តបទល្មើស ឬ

    ២.២ អំពាវនាវឲ្យប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម

៣. បទល្មើសនេះមិនទាមទារឲ្យមានលទ្ធផលទេ ឧទាហរណ៍ ការស្រែកអំពាវនាវឲ្យប្រព្រឹត្តបទឧក្រិដ្ឋមិនចាំបាច់មានអ្នកធ្វើតាមការស្រែកអំពាវនាវនោះទេ ក៏បទល្មើសនោះកើតមានជាស្រេច។

ក្នុងករណីលោក មុិច ដារ៉ា នេះ យើងត្រូវរកអង្គហេតុទាំងអស់ខាងលើដើម្បីកំណត់ថា តើមានបទល្មើសញុះញង់ដែរឬទេ ?

១. តើមានអង្គហេតុដែលបញ្ជាក់ការប្រើពាក្យសំដី, សំណេរ, ឬ គំនូរ ជាសាធារណៈដែរ ឬទេ ? ចម្លើយគឺថាមាន ដោយសារលោក មុិច ដារ៉ា ជាអ្នកសារព័ត៌មាន បានផ្សាយក្នុងគេហទំព័ររបស់ខ្លួន និង បណ្តាញសង្គម ។ តើលោក មុិច ដារ៉ា បានប្រើសំដីអំពាវនាវនេះ អំពាវនាវនោះ (ដូចជា សុំឲ្យធ្វើសកម្មភាពនេះ ឬ នោះ ។ល។) ។ ការសម្តែងមតិក្នុងបណ្តាញសង្គម មិនមែនជាការអំពាវនាវឲ្យប្រព្រឹត្តបទល្មើសទេ ហេតុនេះ ប្រសិនមិនមានពាក្យសំដី ឬ សំណេរ ឬ គំនូរ ញុះញង់ឲ្យប្រព្រឹត្តបទល្មើស នោះ មិនមានបទល្មើស ញុះញង់ តាមមាត្រា ៤៩៤ និង ៤៩៥ ខាងលើនេះទេ។

២. តើពាក្យស្រែក សំណេរ ឬ ការផ្សាយទាំងនោះ ថាដូចម្តេច ?

អំពីពាក្យបន្លឺឲ្យប្រព្រឹត្តបទឧក្រិដ្ឋ

បទល្មើសដែលទម្ងន់ទោសជាឧក្រិដ្ឋត្រូវបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ និង ច្បាប់ព្រហ្មទណ្ឌដទៃទៀត ។ យោងតាមមាត្រា ២២ នៃក្រមព្រហ្មទណ្ឌ បទឧក្រិដ្ឋគឺ៖

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរិមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ៖

១, ជាទោសដាក់ពន្ធនាគារអស់មួយជីវិត។

២. ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

បទល្មើសជាបទឧក្រិដ្ឋមានដូចជា៖

- វចាត់តាំងជាក្រុមដើម្បីប្រើវិធីបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ (មាត្រា ៤១៦)
- វប្រើហិង្សាដែលធ្វើឲ្យមានពិការភាពអចិន្ត្រៃយ៍ដល់អ្នកដទៃ (មាត្រា ២២៣)
- អំពើលួចដោយមានការប្រើអំពើឃោឃៅ នៅមុន ក្នុងពេល ឬក្រោយពេលលួច (ពោលគឺប្លន់) មាត្រា ៣៥៩)
- បទសម្លាប់មនុស្សដោយចេតនា (មាត្រា ១៩៩)

បទល្មើសញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម នឹងកើតមាន នៅពេលដែលជនណាម្នាក់ បានស្រែកអំពាវនាវឲ្យអ្នកចូលរួមដទៃទៀតប្រព្រឹត្តបទឧក្រិដ្ឋ ដូចជាបទល្មើសដែលលើកជាឧទាហរណ៍ ខាងលើជាដើម ។ ដូច្នេះ ដើម្បីដឹងថាមានបទល្មើសញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម គេត្រូវមានភស្តុតាងនៃពាក្យសំដីដែលស្រែកបន្លឺ ឬ សរសេរ ទៅកាន់អ្នកត្រូវញុះញង់ឬសាធារណៈ ហើយយកពាក្យសំដីនោះមកវិភាគ តើពាក្យសំដី ឬសំណេរ ឬ រូប នោះចូលក្នុងនិយមន័យនៃបទល្មើសណាមួយដែលមានលក្ខណៈទោសជាបទឧក្រិដ្ឋដែរឬទេ ឬ ជាការបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គមឬទេ ។ បើមិនមានពាក្យបែបនោះទេ នោះបទញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋក៏គ្មានដែរ ។

អំពីពាក្យដែលអំពាវនាវឲ្យប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម

គ្មាននិយមន័យផ្លូវច្បាប់អំពីពាក្យ “សន្តិសុខសង្គម” ទេ។ ពាក្យនេះ អាចថា សន្តិសុខជាតិទាំងមូល ឬ សន្តិសុខនៃផ្នែកណាមួយនៃជាតិ។ បើពាក្យនេះមានន័យដល់ “សន្តិសុខជាតិ” សូមមើលនិយមន័យនៃពាក្យសន្តិសុខជាតិដែលពិពណ៌នាខាងក្រោម៖

ពាក្យថាគ្មានសន្តិសុខ គឺអសន្តិសុខ គឺភាពនៃការរស់នៅក្នុងការភ័យខ្លាច ដោយសារសង្គមមួយ គ្មានការគោរពច្បាប់ មនុស្សធ្វើអ្វីតាមចិត្ត អំណាចសាធារណៈមិនអាចគ្រប់គ្រងបាន។

មាត្រា ៤៩៥ មិនសំដៅអសន្តិសុខតូចតាចទេ តែជាអសន្តិសុខធ្ងន់ធ្ងរ។ ដូចគ្នានឹងការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋដែរ ដើម្បីកំណត់ពីបទល្មើសញុះញង់ឲ្យប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម គេត្រូវមានភស្តុតាងនៃពាក្យដែលញុះញង់នោះ តើលោក មិច ដារ៉ា បានស្រែកឬសរសេរពាក្យអ្វីខ្លះ ហើយយកពាក្យនោះមកវិភាគ តើពាក្យនោះចូលជាពាក្យនាំមានអ្នកចូលរួមបង្កភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម

ដែរឬទេ ។ បើរកពាក្យទាំងនោះមកបង្ហាញមិនបាន នោះ បទញុះញង់ឲ្យប្រព្រឹត្តអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ក៏គ្មានដែរ។

បើគ្មានភស្តុតាងនៃពាក្យសំដី ជាសំណេរ ជាគំនូរនោះទេ នោះមិនមានអត្ថិភាពនៃបទល្មើសញុះញង់ដោយផ្ទាល់ទេ ។ បើគ្មានបទល្មើសញុះញង់ទេ ការចោទប្រកាន់របស់អាជ្ញាធរ ឬ តុលាការ គឺគ្មានមូលដ្ឋានទេ ។

ក្រុមអ្នកតស៊ូមតិកម្ពុជា សន្និដ្ឋានថា ការចាប់ខ្លួន ចោទប្រកាន់ និង ឃុំខ្លួនលោក ម៉ិច ដារ៉ា គឺគ្មានមូលដ្ឋានច្បាប់ និង អង្គហេតុទេ ហេតុនេះសកម្មភាពបំពេញទម្រង់ឃុំខ្លួនលោក ម៉ិច ដារ៉ា គឺជា អំពើចាប់ខ្លួនមនុស្សតាមអំពើចិត្ត និង ជាការរំលោភសិទ្ធិមនុស្សរបស់លោក លោក ម៉ិច ដារ៉ា ។

ក្រុមអ្នកតស៊ូមតិកម្ពុជា សូមអំពាវនាវឲ្យចៅក្រមស៊ើបសួរ សម្រេចទម្លាក់បទចោទចំពោះលោក ម៉ិច ដារ៉ា និង ដោះលែងគាត់វិញ ទើបជាការនៅមានការគោរពច្បាប់ខ្លះ ។
ទោះយ៉ាងណាក្តី ក្រុមអ្នកតស៊ូមតិកម្ពុជា យល់ថា អ្វីៗទាំងអស់គឺស្ថិតក្នុងដៃរបស់លោក **ហ៊ុន សែន** និង ក្រុមគ្រួសារ ដែលបានយកគណបក្សប្រជាជន ជាអង្គការចាត់តាំងនយោបាយដឹកនាំ ជ្រៀតជ្រែកក្នុងគ្រប់វិស័យ ដែលបានបង្កអស្ថេរភាពរដ្ឋបាលក្នុងម៉ាស៊ីនរដ្ឋបាលរបស់រដ្ឋគ្រប់ជាន់ថ្នាក់។ ការគាបសង្កត់មន្ត្រីរាជការឲ្យចូលជាសមាជិកគណបក្សប្រជាជន រួមទាំងចៅក្រម ព្រះរាជអាជ្ញារ កងកម្លាំងប្រដាប់អាវុធផង បានដាក់ប្រទេសកម្ពុជា ចូលក្នុងស្ថានភាពរបបផ្តាច់ការ និង មិនអាចមានការរីកលូតលាស់ផ្នែកសិទ្ធិមនុស្ស និង សេដ្ឋកិច្ចបានទេ ។

យើងខ្ញុំគ្រាន់តែជាក្រុមវិភាគ នៃក្រុមអ្នកតស៊ូមតិកម្ពុជា មានតែប្រគល់តួនាទីតាមដាន និង ត្រួតពិនិត្យជូនប្រជាពលរដ្ឋគ្រប់ៗគ្នាទាំងក្រៅនិងក្នុងប្រទេសក្នុងរឿងនេះបន្តទៀត ដើម្បីស្តារលទ្ធិប្រជាធិបតេយ្យ និង នីតិរដ្ឋជូនប្រជាពលរដ្ឋខ្មែរវិញ រួមទាំងការដោះលែងអ្នកនយោបាយ សកម្មជនសង្គម និង លោក ម៉ិច ដារ៉ា ផង។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*
**ប្រធានក្រុមអ្នកតស៊ូមតិកម្ពុជា**(CAT) **លោក ហុខ លឹម** តាមរយៈទូរស័ព្ទ និង Signal: +61 418 551 223